ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៣០/១៨ របក

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែមករា និងទិសដៅខែកុម្ភៈ ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ក្នុងខែមករា ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូនានា ជាពិសេសលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី រហូតដល់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានមានប្រសាសន៍នៅក្នុងកម្មវិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តបាត់ដំបង និងបានបញ្ជាក់ថាៈ"**ឆ្នាំ២០១៨ ត្រូវបិទច្រករបៀងឲ្យបាន**" ពីព្រោះវាមិនមែនតែទំនិញគេចពន្ធ និងគ្រឿងញៀននោះទេ វាជាច្រកមានការរត់ពន្ធមនុស្ស ជួញដូរមនុស្ស ដែលជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋយើង ត្រូវបានគេនាំចេញទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ រហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់លាស់ និងការខាតបង់ថវិកាជាតិរាប់លានដុល្លារ។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ធ្វើការខុសច្បាប់ក្នុងប្រទេសថៃរួចមក ដើម្បីជាដំណោះស្រាយ ប្រមុខរាជរដ្ឋាភិបាលរបស់យើង បានយកចិត្តទុកដាក់បំផុតចំពោះប្រជាពលរដ្ឋ ធ្វើទេសន្តរប្រវេសយ៍នៅក្រៅប្រទេស និងបានសហការជាមួយរដ្ឋាភិបាលថៃ ក្នុងការជំរុញឲ្យមានការរៀបចំផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ជាពិសេសត្រូវបានពិភាក្សាជាមួយភាគីថៃ ដើម្បីការការពារសុវត្ថិភាព សិទ្ធិការងារ ក្នុងនោះរួមមានរបបគ្រោះថ្នាក់ការងារ របបថៃទាំសុខភាព និងប្រាក់សោធននិវត្តន៍ជូនដល់ពលករកម្ពុជា ឲ្យដូចគ្នានឹងពលករថៃដែរ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបាន ៖

- ពីបណ្ដាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ក្រុមការងារការពារជនរងគ្រោះ) អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) អគ្គនាយកដ្ឋានអន្តោប្រវេសន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ផ្ដល់របាយការណ៍។
- សម្រាប់បណ្ដាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋាន គ.ខ.ប.ជ **២៥**រាជធានី-ខេត្ត បានផ្ដល់របាយការណ៍។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែមករា ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

# ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

## ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

### ក.១-ការងារច្បាប់ គោលនយោបាយលិខិតបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការសម្រេចបានឆ្នាំ២០១៧

#### ក.១-ច្បាប់ គោលនយោបាយលិខិតបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការ

**ក.១.១-សេចក្ដីព្រាងច្បាប់ដែលកបានចុះហត្ថលេខារួចហើយ៖**

- **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយភាគីឥណ្ឌា ស្ដីពី"**អនុស្សរណៈនៃការយោគយល់គ្នាស្ដីពីការទប់ស្កាត់ការជួញដូរមនុស្ស**" (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧)។
- **ក្រសួងយុត្តិធម៌** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយភាគីឥណ្ឌាស្ដីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧)។

**ក.១.២-សេចក្ដីព្រាងច្បាប់ដែលកំពុងរៀបចំ៖**

- សេចក្ដីព្រាងច្បាប់ ស្ដីពី"**ការពពោះជំនួស**"(ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌)។
- **ក្រសួងយុត្តិធម៌**បានរៀបចំសេចក្ដីព្រាងច្បាប់ចំនួន០២គឺ៖
  - ស្ដីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្ដីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

**ក.១.៣-លិខិតបទដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិកំពុងរៀបចំ៖**

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្ដីព្រាងចុះលើសន្ធិសញ្ញា ទ្វេភាគីរួមមាន៖

  រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ

  រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង

  រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - **សេចក្ដីព្រាងសន្ធិសញ្ញា ស្ដីពី"បត្យាប័ន"**

    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - **សេចក្ដីព្រាង កិច្ចព្រមព្រៀង ស្ដីពី "បញ្ជូនទណ្ឌិត"**

    រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស

    រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ

    រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

Aitha

ក.១.៤-**លិខិតបទដ្ឋានជាតិកំពុងរៀបចំ៖**

- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។
- សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)។
- សេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។

❖ **អនុស្សរណៈរវាងអង្គការដៃគូកំពុងរៀបចំ៖**

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការអន្តរជាតិ GVC ស្តីពីការគាំទ្រ និងការតស៊ូមតិលើសិទ្ធិពលករទេសន្តរប្រវេសន៍ កម្ពុជា ក្នុងប្រទេសថៃ ដើម្បីទប់ស្កាត់ការរំលោភបំពានអំពើជួញដូរមនុស្ស។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយតាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន០៥ គឺប៉ុស្តិ៍ ច្រកប៉ោយប៉ែត ច្រកដូង ច្រកព្រំ ច្រកអូរស្មាច់ និងច្រកជាំ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន**១៩.៤០៨**ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន (**របាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍**)។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែមករា ឆ្នាំ២០១៨នេះ **ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** អាជ្ញាធរ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោលបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន**៤.២៥២**លើក មានអ្នកចូលរួមសរុបចំនួន**២៦៧.១១៥**នាក់ (ធៀបនឹងខែធ្នូ ឆ្នាំ២០១៦ មានចំនួនត្រឹមតែ**១២៦.៥៨៧**នាក់) កើនឡើងចំនួន**១៤០.៥២៨**នាក់ ស្មើនឹង**១១១.០១%** ក្នុងនោះស្ត្រីមានចំនួន**១៣៥.៣៧២**នាក់។ (**ឧបសម្ព័ន្ធទី១**)

**ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន**

- **លេខាធិការដ្ឋានគ.ខ.ប.ជខេត្ត** បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន២២៦លើក (ខេត្តកោះកុង៣១លើក, សៀមរាប០១លើក, កំពង់ចាម០១លើក និងបាត់ដំបង០១លើក)។
- **ខេត្តសៀមរាប៖**
    - **អង្គការ Friend International** គម្រោងកល្យាណមិត្ត បានធ្វើការចែកខិត្តប័ណ្ណ និងសំភារៈផ្សព្វផ្សាយដែលមានខ្លឹមសារទាក់ទាងនឹងកិច្ចការពារកុមារ មានដូចជា៖
        - គន្លឹះទាំង៧សម្រាប់ជួយដល់កុមារ ចំនួន៤៦៦សន្លឹក
        - គន្លឹះទាំង៧សម្រាប់ជនបរទេស ចំនួន៩១៤សន្លឹក
        - កាតទូរស័ព្ទបន្ទាន់ ចំនួន ៨៨៤សន្លឹក
        - ទូរស័ព្ទបន្ទាន់ ចំនួន៤០ផូស្ទើ
        - ភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន៦៣អាវ
        - ភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន១០៦ស្ទីកគ័រ
        - រក្សាកុមារនៅក្នុងគ្រួសារ/សហគមន៍ (មណ្ឌលកុមារកំព្រាធ្វើឲ្យកុមារបែកចេញពីគ្រួសារ) ចំនួន៨៥ផូស្ទើ
        - កុមារមិនមែនជាឧបករណ៍សំរាប់ទាក់ទាញកុមារទេ ចំនួន៨៦សន្លឹក
        - និងបានលើកស្លាកទូរស័ព្ទបន្ទាន់ ចំនួន១២រឺម៉ែកម៉ូតូកង់បី។
- **ខេត្តបាត់ដំបង អង្គការ Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយដល់ពលករចំណាកស្រុក៨៥នាក់ ស្រី២៣នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**ខ.៥-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលខំនោរទៅរកការជួញដូរមនុស្ស**

**ខ.៥.១.-<u>វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការនគរបាលជាតិ</u>**

- វរៈនគរបាលការពារព្រំដែនគោកលេខ(៨១៧, ៨១៩, ៨២៣ និង៣១០) ខេត្តបាត់ដំបង បានធ្វើការទប់ស្កាត់ពលករខ្មែរ ដែលបំរុងធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន០២លើក មនុស្សចំនួន០៦នាក់ ស្រី០២នាក់ អនីតិជន០៣នាក់។

**ខ.៥.២-<u>វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ</u>៖**

អគ្គស្នងការដ្ឋាននគរបាលជាតិ (**របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់**) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៨០៥គោលដៅ មានមនុស្សចំនួន២.២៣៥នាក់ (ស្រី១.៦៣០នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មានខេត្ត៖** (តាកែវ, មណ្ឌលគិរី

Sitha

ស្វាយរៀង, កំពត, កែប, ឧត្តរមានជ័យ, ស្ទឹងត្រែង, ពោធិ៍សាត់, កោះកុង, កំពង់ស្ពឺ, កំពង់ចាម, ព្រះវិហារ, ក្រចេះ និងកំពង់ឆ្នាំង)។

- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន៧៥គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន២៤លើក ខេត្តអនុវត្តមាន៖ ស្វាយរៀង ឧត្តរមានជ័យ ស្ទឹងត្រែង កំពង់ធំ និងព្រៃវែង។
- **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងអង្គការម្លប់តាប៉ាង** បានដាក់បណ្តាញភ្នាក់ងារ ដើម្បីការពារសុវត្ថិភាពកុមារ មានក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បីចំនួន១៤៣នាក់ ផ្ទះសំណាក់ សណ្ឋាគារ២៤កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ៧១នាក់ បណ្តាញតាមសហគមន៍៦០នាក់ ផ្នែកភ្នាក់ងារទេសចរណ៍០២នាក់ សមាជិកបណ្តាញបុគ្គលិកផ្ទះសំណាក់/សណ្ឋាគារ៣៧៤នាក់។
- **ស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងអង្គការ Friend InTernation** គម្រោងកល្យាណមិត្ត បានដាក់បណ្តាញភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ ដល់ក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បីចំនួន៤៥នាក់។

**ខ.៦-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

ខ.៨.១-<u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន៣០០.០៧៧នាក់ (ស្រី១២៧.៧៤៩នាក់) អនីតិជន៨.៤៧៨នាក់ (ស្រី៣.១៦៥នាក់) ក្នុងនោះស្របច្បាប់ចំនួន ១៦៨.០៤២នាក់ (ស្រី៧៤.៦៣៥នាក់) អនីតិជន៩៥៦នាក់ (ស្រី៤២៧នាក់) មិនស្របច្បាប់ចំនួន១៣២.០៣៥នាក់ (ស្រី៥៣.១១៤នាក់) អនីតិជន៧.៥២២នាក់ (ស្រី២.៧៣៨នាក់) បើប្រៀបធៀបនឹងខែមុនមានការថយមានចុះចំនួន២១.៥២០នាក់ ស្មើនឹង៦.៦៩%។

ខ.៨.២-<u>ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន</u>

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់ មកកម្ពុជាវិញចំនួន១៨៥លើក មនុស្សចំនួន៤.៤៣៤នាក់ (ស្រី១.៥៧០នាក់ កុមារ៣៦៦នាក់)។ ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន២៣លើក មនុស្ស៥៩នាក់ ស្រី២៥នាក់, តាម ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន១៦០លើក មនុស្ស៤.៣៤៦នាក់ (ស្រី១.៥២៩នាក់ កុមារ ៣៦៦នាក់) និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន០២លើក មនុស្ស ២៩នាក់ ស្រី១៦នាក់។

<u>*ស្ថានភាព*</u> ៖

- **ក្រុមការងារអនុវត្តន៍ច្បាប់**បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន៣១០នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វាអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន៨៨ជើង/រថយន្ត មាន

Retha

មនុស្សចំនួន៣.៣៨៩នាក់ ស្រី២៥.៥៨០នាក់ ក្នុងនោះកុមារ២៨១នាក់ កុមារី១៥២នាក់។ បើប្រៀបធៀបនឹងខែធ្នូ ឆ្នាំ២០១៧ គឺមានការកើនឡើងចំនួន២២៤នាក់ ស្មើនឹង៧.០៧%។

- ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន១.០០៩នាក់ តាមច្រករបៀងមាន២.៣៨០នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន១.៣៤១នាក់ និងតាមគេនាំ មាន២.០៤៨នាក់។
- តាមការសម្ភាសន៍៖ កុមារ៨៩នាក់ (កុមារី៣០នាក់) ទៅតាមឪពុកម្តាយ៧៥នាក់ និង១៤នាក់ ទៅតាមបងប្អូន។

- **ខេត្តបាត់ដំបង** បានទទួលពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់មកវិញ ចំនួន០៨លើក មនុស្សចំនួន១៧នាក់ ស្រី០៤នាក់ កុមារ០១នាក់។
- **ខេត្តប៉ៃលិន** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន៣១លើក មនុស្សចំនួន២៩២នាក់ ស្រី១០៦នាក់។
- **ដោយឡែក** យោងរបាយការណ៍**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសធ្វើការនៅកម្ពុជាដោយខុសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១-**ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់:** ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន៤៨លើក មនុស្សចំនួន៩១នាក់ ស្រី០៥នាក់ មាន២៥សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន២៣លើក មនុស្ស៥៨នាក់ ស្រី០៥នាក់ មាន១១សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេសតាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន២៥លើក មនុស្ស៣៣នាក់ មាន២៥សញ្ជាតិ។

២-**បទល្មើសស្នាក់នៅខុសច្បាប់ចំនួន០៣លើក** មនុស្សចំនួន០៣នាក់ មានសញ្ជាតិ៖ (បារាំង០១នាក់ រុស្ស៊ី០១នាក់ និងអូស្ត្រាលី០១នាក់)។

### ខ.៩-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន១២០គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន១០ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាល

Sitha

ជាតិក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋានរាជធានី-ខេត្ត (រាជធានីភ្នំពេញ, បន្ទាយមានជ័យ, បាត់ដំបង, កំពង់ចាម, កំពង់ឆ្នាំង, កណ្តាល, ព្រះសីហនុ, និងខេត្តតាកែវ)។

**គ.១-ការងារអនុវត្តច្បាប់**

គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន**១៤**/០៨ករណី (បើប្រៀបធៀបនឹងខែមុនកើនឡើង**០៦**ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន**១៥**នាក់ (ស្រី**០៤**នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន**០១**នាក់និងជនបរទេសសញ្ជាតិអូស្ត្រាលី **០១**នាក់។ យើងបានសង្គ្រោះជនរងគ្រោះចំនួន**៣១**នាក់ មានអាយុក្រោម១៥ឆ្នាំ**០៩**នាក់ អាយុពី១៥-១៧ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង**២០**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**១៨**នាក់ និងគ្រួសារចំនួន**១៣**នាក់)។

**១.ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន**០៤**/០៣**ករណី** (កើន**០១**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន**០៤**នាក់ (ស្រី**០២**នាក់) សង្គ្រោះជនរងគ្រោះចំនួន**០៤**នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ**០២**នាក់ អាយុពី១៥-១៧ឆ្នាំ**០១**នាក់ និងអាយុ១៨ឆ្នាំឡើង**០១**នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| **បទល្មើស** | **ករណី** | **ជនសង្ស័យ** |
|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០៣ | ០៣ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ |
| ***សរុប*** | ***០៤ ករណី*** | ***០៤ នាក់*** |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន**១០**/០៥**ករណី** (កើន**០៥**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន**១១**នាក់ (ស្រី**០២**នាក់) ជនសង្ស័យជាអនីតិជន**០១**នាក់និងជនបរទេសសញ្ជាតិអូស្ត្រាលី**០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន**២៧**នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ**០៧**នាក់ និងអាយុ១៨ឆ្នាំឡើង**១៩**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**១៨**នាក់ និងទៅគ្រួសារ**០៩**នាក់។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| **បទល្មើស** | **ករណី** | **ជនសង្ស័យ** | **ជនបរទេស** |
|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | អូស្ត្រាលី១ |
| -សញ្ចារកម្ម | ០១ | ០២ | |
| -សញ្ចារកម្ម (មានអនីតិជន) | ០២ | ០២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | |
| -អំពើអាសប្រាតនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | |
| ***សរុប*** | ***១០ ករណី*** | ***១១ នាក់*** | ***០១ នាក់*** |

Ritha

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ

- យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការ IOM មានចំនួន២៩នាក់ មកពី ៖

- ប្រទេសម៉ាឡេស៊ី ចំនួន២២នាក់
- ប្រទេសវៀតណាម ចំនួន០៧នាក់ (ស្រី)

*ស្ថាប័ន-អង្គភាពអនុវត្តមាន ៖*

- **អង្គការ IOM** ក្នុងខែមករា ឆ្នាំ២០១៨នេះ បានជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋ ពលករពលការនីរងគ្រោះចំនួន១១នាក់ មកពីប្រទេសម៉ាឡេស៊ី។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់)** បានទទួលពលករខ្មែររងគ្រោះចំនួន០៨នាក់(ស្រី) ក្នុងនោះមកពីប្រទេសចិន០៥នាក់, ម៉ាឡេស៊ី០១នាក់ និងប្រទេសអារ៉ាប៊ីសាអូឌី០១នាក់។ តាមការសម្ភាសមានទៅតាមមេខ្យល់០៥នាក់ និងទៅតាមក្រុមហ៊ុន០៣នាក់។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន៩០នាក់ (ស្រី៥៣នាក់ កុមារា២៤នាក់ កុមារី១១នាក់) ។ មានដូចខាងក្រោម៖

- **ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដោយមានកិច្ចសហការជាមួយអង្គការ IOM អង្គការចាប់ដៃ អង្គការរតេនៈ និងអង្គការសព័ន្ធចាប់ដៃ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន២១នាក់ (ស្រី១០នាក់) មកពីប្រទេស៖ ម៉ាឡេស៊ី១៤(ករណីជួញដូរកម្លាំងពលកម្ម) និងវៀតណាម០៧នាក់(ករណីជួញដូរផ្លូវភេទ)។
- **មន្ទីរស.អ.យ រាជធានីភ្នំពេញ** បានទទួលជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន៣២នាក់ (ស្រី២១នាក់ កុមារា១៤នាក់ កុមារី០៧នាក់) ក្នុងនោះ(ករណីធ្វើអាជីវកម្មផ្លូវភេទ៣០នាក់ និងជួញដូរកម្លាំងពលកម្ម០២នាក់)។
- **មន្ទីរស.អ.យ ខេត្តបន្ទាយមានជ័យ** បានទទួលជនងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៨នាក់ (ស្រី០១នាក់ កុមារា០៥ កុមារី០២នាក់) ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សប្រទេសថៃ(DSDW) ឲ្យរស់នៅក្នុងមណ្ឌលសំចតប៉ោយប៉ែតរយៈពេលខ្លី ក្នុងនោះ០៣នាក់(បុរស)ករណីជួញដូរកម្លាំងពលកម្មលើទូកនេសាទ។
- **មន្ទីរស.អ.យ ខេត្តស្វាយរៀង** បានទទួលជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសវៀតណាមចំនួន២៩នាក់ (ស្រី២១នាក់ កុមារា០៥ កុមារី០២នាក់)ករណីកេងប្រវ័ញ្ចពលកម្ម។

**ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- **សមាហរណកម្មជនរងគ្រោះ**

- **ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្រោយពីការស្នាក់នៅមណ្ឌលសំចតប៉ោយប៉ែតរយៈពេលខ្លីរួចមក បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន៣៤នាក់ (ស្រី១១នាក់ កុមារា១៤នាក់ កុមារី០៧នាក់) ទៅអង្គការដៃគូ ដើម្បីទទួលបានសេវាស្នាក់នៅសុវត្ថិភាព អប់រំក្នុង និងក្រៅប្រព័ន្ធ មានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសេវាផ្សេងៗ ។ ហើយបានធ្វើសមាហរណកម្មជនរងគ្រោះចំនួន១០នាក់(ស្រី០២នាក់) មានករណីជួញដូរកម្លាំងពលកម្ម០៩នាក់ និងរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០១នាក់ ទៅសហគមន៍របស់ពួកគាត់វិញ ដោយមានការជួយឧបត្ថម្ភពីអង្គការរតនៈ ទាំងការហូបអាហារ និងមធ្យោបាយធ្វើដំណើរ ។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការបណ្តុះបណ្តាលក្នុងប្រទេស

លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តចំនួន០១ គឺមានខេត្តព្រះសីហនុ មណ្ឌលគិរី និងខេត្តសៀមរាប បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន៨០នាក់ ក្នុងនោះមានស្ត្រី៤២នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ឌ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **ខេត្តព្រះសីហនុ មន្ទីរទេសចរណ៍** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបដិសណ្ឋារកិច្ច សេវាកម្មអាហារ និងភេសជ្ជៈ ចំនួន០២ថ្ងៃ នៅភូមិកោះតូច សង្កាត់កោះរ៉ុង សន្លឹម ក្រុង-ខេត្តព្រះសីហនុ។ | ០១ | ២៦ | ១៦ |
| ២ | **ខេត្តមណ្ឌលគិរី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ០១ | ៥០ | ២៦ |
| ៣ | **ខេត្តសៀមរាប អង្គការ Friend International** គម្រោងកល្យាណមិត្ត បានបណ្តុះបណ្តាលដល់ភ្នាក់ងារដើម្បីការពារសុវត្ថិភាពកុមារ ជាផ្នែកជួយគាំទ្រការរាយការណ៍ សង្គ្រោះជនរងគ្រោះ ដល់ក្រុមគោលដៅ។ | ០១ | ០៤ | |
| **សរុប** | | **០៣** | **៨០** | **៤២** |

#### ១.៤-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ ៖

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ៣៦លើក មានអ្នកចូលរួមសរុប៥៦០នាក់ មានស្រី២៣៩នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន១៨លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន០៦លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន១៤លើក ។ (**ឧបសម្ព័ន្ធទី២**)

### ២. ក្រៅប្រទេស

#### ២.១-កិច្ចប្រជុំ

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួម

ជាគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋឥណ្ឌា ដែលក្នុងដំណើរទស្សនកិច្ចនោះ **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយភាគីឥណ្ឌានូវ "**អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស**" ។

- **ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត** អគ្គនាយកអន្តោប្រវេសន៍ បានដឹកនាំប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អមដំណើរ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបំពេញទស្សនកិច្ចនៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖ Putha

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ ដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកុម្ភៈ ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្ដាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៥. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៨. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៩. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១០. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។ Ritha

១១. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១២. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖

១៣. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៤. បង្កើតក្រុមការងារពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៥. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៦. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ..................ខែ..........ឆ្នាំ..........នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែមករា ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 1,073 លើក | 62,334 នាក់ | 34,920 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 376 លើក | 53,317 នាក់ | 23,347 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក | 21 លើក | 2,864 នាក់ | 1,679 នាក់ |
| 3 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 68 លើក | 2,313 នាក់ | 838 នាក់ |
| | | ផ្សព្វផ្សាយការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរកិច្ចការនារីខេត្ត | 124 លើក | 5,704 នាក់ | 1,902 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 150 លើក | 7,671 នាក់ | 3,894 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 366 លើក | 42,467 នាក់ | 23,623 នាក់ |
| 5 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពី ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 619 លើក | 25,671 នាក់ | 13,057 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 273 លើក | 8,327 នាក់ | 4,240 នាក់ |
| 6 | ខេត្តស្វាយរៀង | ផ្សព្វផ្សាយ ស្តីពីការចំណាកស្រុកដោយសុវត្ថិភាព ដល់កម្មករ កម្មការិនី នៅរោងចក្រ AMPAC តំបន់សេដ្ឋកិច្ចពិសេសមេនហាធេន។ | មន្ទីរការងារ និងបណ្តុះបណ្តាលខេត្ត | 1 លើក | 50 នាក់ | 20 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 310 លើក | 10,275 នាក់ | 5,343 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 435 លើក | 15,904 នាក់ | 8,090 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់កម្មករ និយោជិកនៅតាមរោងចក្រ និងអំពើជួញដូរមនុស្ស ដល់សិស្ស និស្សិតនៅមណ្ឌលបណ្ដុះបណ្ដាលជីផ្ជាជីវៈខេត្ត។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរការងារ និងបណ្ដុះបណ្ដាលខេត្ត | 367 លើក | 19,383 នាក់ | 9,488 នាក់ |
| 8 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត និងកងរាជអាវុធហត្ថខេត្ត | 6 លើក | 1,371 នាក់ | 708 នាក់ |
| 9 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ ស្ដីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 45 នាក់ | 37 នាក់ |
| 10 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 32 លើក | 1,752 នាក់ | 907 នាក់ |
| 11 | ខេត្តកែប | ផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 20 លើក | 6,981 នាក់ | 3,060 នាក់ |
| 12 | ខេត្តរតនគិរី | ផ្សព្វផ្សាយទៅដល់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនសិប្បកម្ម នានាក្នុងខេត្ត ឲ្យអនុវត្តតាមច្បាប់ ស្ដីពីការងារ ដល់កម្មករ និងនិយោជិត។ | មន្ទីរការងារ និងបណ្ដុះបណ្ដាលខេត្ត | 9 លើក | 258 នាក់ | |
| 13 | ខេត្តព្រះសីហនុ | វេទិកាសាធារណៈ ស្ដីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ក្រុមការងារគ.ខ.ប.ជខេត្ត និងអាជ្ញាធរក្រុង/ស្រុក | 1 លើក | 428 នាក់ | 219 នាក់ |

**សកម្មភាពសរុបចំនួន:** 4,252 លើក

**មនុស្សសរុបចំនួន:** 267,115 នាក់

**ស្រីសរុបចំនួន :** 135,372 នាក់

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៣៦លើក) មនុស្សចំនួន៥៦០នាក់ (ស្រី២៣៩នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | **សម្របសម្រួលចំនួន១៨លើក អ្នកចូលរួមសរុបចំនួន៦២នាក់ (ស្រី១៣នាក់)**<br>❖ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យលើ នីតិវិធីស្តីពីការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងពលរដ្ឋខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីករណីពពោះជំនួសក្នុងដំណាក់កាលមិនទាន់មានច្បាប់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន២៤នាក់ ស្រី០៥នាក់។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងជាមួយអង្គការចាប់ដៃ ស្តីពីការងារពាក់ព័ន្ធអំពើជួញដូរមនុស្ស និងត្រៀមចុះអនុស្សរណៈយោគយល់គ្នា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន០៦នាក់ ស្រី០១នាក់។<br>- បានអញ្ជើញចូលរួមក្នុងពិធីសម្ភោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សាថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅបណ្ឌិត្យសភានគរបាលកម្ពុជា។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន០២លើក ស្តីពីការត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន៣២នាក់ ស្រី០៧នាក់។<br>- បានដឹកនាំកិច្ចប្រជុំ ស្តីពីការបិទសន្និបាតឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ដែលនឹងប្រព្រឹត្តទៅនៅខេត្តកំពង់ឆ្នាំង និងខេត្តកែប នៅសាលប្រជុំអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។<br>❖ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ប៉េង សំអាត** អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបវឌ្ឍនៈភាពនៃការងារអគ្គសញ្ញាណកម្មរយៈពេល៣ឆ្នាំ (២០១៤-២០១៧) នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ នៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង។<br>- បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ នៅខេត្តកំពង់ធំ និងខេត្តសៀមរាប។<br>- បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ នៅខេត្តព្រៃវែង។<br>- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់មន្ត្រីនគរបាលជាតិ និងមន្ត្រីស៊ីវិល នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ រៀងរាល់សប្តាហ៍ថ្ងៃច័ន្ទ។<br>❖ ក្រុមជំនួយកិច្ចការទាំង០៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ<br>- លោកឧត្តមសេនីយ៍ទោ **ស្រី សាមឌី** ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ និងលោកឧត្តមសេនីយ៍ត្រី **កែវ សុវណ្ណារ៉ា** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមសិក្ខាសិលា ស្តីពីទេសន្តរប្រវេសន៍កុមារ និងផលប៉ះពាល់លើកុមារទេសន្តរប្រវេសន៍ដែលគ្រួសារមិនបានទៅជាមួយ រៀបចំដោយអង្គការ IOM។ |

| | |
|---|---|
| | - ឯកឧត្តម ឧត្តមសេនីយ៍ទោ **ជីវ ផល្លី** អគ្គលេខាធិការរង បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុម ស្តីពីការងារដឹកនាំរបស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។<br>- លោកឧត្តមសេនីយ៍ត្រី **កែវ សុវណ្ណារ៉ា** ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមពិធីបិទសន្និបាតការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង។<br>- ឯកឧត្តម ឧត្តមសេនីយ៍ទោ **ជីវ ផល្លី** អគ្គលេខាធិការរង បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុម ត្រួតពិនិត្យរបាយការណ៍ឆ្នាំ២០១៧ របស់ក្រុមការងារបង្ការ ទប់ស្កាត់ និងកែសម្រួល ផែនការសកម្មភាពឆ្នាំ២០១៨ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យផ្តល់យោបល់ និងបំពេញបន្ថែមនូវធាតុចូលលើកចុងក្រោយ លើរបាយការណ៍អំពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ នៅទន្លេបាសាក់២។<br>- លោកវរៈសេនីយ៍ឯក **អ៊ិន មាន** ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិស្តីទី បានធ្វើបទបង្ហាញលើការប្រើប្រាស់វិធី ដើម្បីចងក្រងទិន្នន័យ និងការរក្សាទុក ព្រមទាំងធ្វើការណែនាំពន្យល់ពីគម្រោងថ្មី នៃគេហទំព័របិសាយគ្រប់គ្រងប្រព័ន្ធទិន្នន័យបច្ចុប្បន្នដៃគូអភិវឌ្ឍន៍ផងដែរ។<br>- បានចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោងស្តីពីការពិនិត្យ និងរៀបចំផែនការសកម្មភាពបន្តសំរាប់អនុវត្តគម្រោង ILO-TRIANGLE នៅសណ្ឋាគារភ្នំពេញ ក្រោមការរៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការផ្នែកបច្ចេកទេសដោយអង្គការ ILO។ |
| **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | ❖ ឯកឧត្តម នាយឧត្តមសន្តិបណ្ឌិត **សុខ ផល** អគ្គនាយកដ្ឋានអន្តោប្រវេសន៍<br>- បានអញ្ជើញចូលរួមប្រជុំពិភាក្សាដើម្បីត្រៀមរៀបចំសម្របសម្រួលខ្លឹមសារកំណត់ហេតុ នៃកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(S) ក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិនិត្យករណីពាក់ព័ន្ធបទល្មើសបរិហារកេរ្តិ៍ និងជេរប្រមាថអង្គព្រះមហាក្សត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមធ្វើសេចក្តីរាយការណ៍អំពីការងាររបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការវិភាគមុខងារ ការកំណត់ក្របខ័ណ្ឌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ក្រសួងមហាផ្ទៃ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន១៤លើក អ្នកចូលរួមសរុបចំនួន៤៩៨នាក់ (ស្រី២២៦នាក់)** | |
| **ខេត្តកណ្តាល** | - ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែធ្នូ ចំនួន០៥លើក អ្នកចូលរួមចំនួន១១១នាក់ ស្រី៧៥នាក់។<br>- លេខាធិការដ្ឋានខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបការងារឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នកចូលរួមចំនួន៦២នាក់ ស្រី២៦នាក់។ |
| **ខេត្តសៀមរាប** | - កិច្ចប្រជុំពិភាក្សាចំនួន០៣លើក ស្តីពីការបូកសរុបឆ្លុះបញ្ចាំងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ និងលើកទិសដៅឆ្នាំ២០១៨ អ្នក |

| | |
|---|---|
| | ចូលរួមចំនួន២៦៩នាក់ ស្រី១១០នាក់។ |
| **ខេត្តពោធិ៍សាត់** | - បានចាត់បញ្ជូនមន្ត្រីនគរបាល០១រូប នៃស្នងការដ្ឋាននគរបាលខេត្ត ទៅចូលរួមវគ្គហ្វឹកហ្វឺនជំនាញស៊ើបអង្កេត បទល្មើសជួញដូរមនុស្ស នៅរាជធានីភ្នំពេញ។ |
| **ខេត្តឧត្តរមានជ័យ** | - បានចូលរួមកិច្ចប្រជុំ គ ក ស ក នៅសាលាខេត្ត អ្នកចូលរួមចំនួន២៥នាក់ ស្រី១១នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែមករា ស្តីពីការពង្រឹងសមត្ថភាព និងវាយតម្លៃលទ្ធផលការងាររបស់សមាជិក គ.ខ.ប.ជ.ខេត្ត អ្នកចូលរួមចំនួន១១នាក់ ស្រី០៥នាក់។ |
| **ខេត្តតាកែវ** | - កិច្ចប្រជុំក្រុមការងារថ្នាក់ស្រុកនៅស្រុកព្រៃកប្បាស អំពីយន្តការពង្រឹងការងារជួញដូរមនុស្ស និងការរំលោភសេពសន្ថវៈ។ |
| **ខេត្តមណ្ឌលគិរី** | - បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យ ការអនុវត្តគោលការណ៍របស់អគ្គស្នងការនគរបាលជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧។ |